# តើព្រះយេស៊ូវបានបង្រៀនអ្វីខ្លះ អំពីការគោរពឪពុកម្ដាយ?

និពន្ធ និងរៀបរៀងដោយ

សមាគមស្វែងរកប្រាជ្ញាព្រះគម្ពីរព្រះយេស៊ូវ

ស្វែងរកប្រាជ្ញា ស្គាល់ព្រះជាម្ចាស់ គោរពសេចក្ដីពិត

www.facebook.com/SeekingtheWisdomofJesusinKhmer

© រក្សាសិទ្ធិ ២០១៨

# តើព្រះយេស៊ូវបានបង្រៀនអ្វីខ្លះ អំពីការគោរពឪពុកម្ដាយ?

សំណួរនេះគឺជាសំណួរមួយដ៏សំខាន់ ដែលអ្នកមិនទាន់បានជឿលើព្រះយេស៊ូវភាគច្រើន តែងតែសួរទៅកាន់អ្នកជឿលើព្រះអង្គ។ សំណួរនេះល្អ ហើយយើងទាំងអស់គ្នាត្រូវការចម្លើយ ពីព្រោះយើងបានឮ តាំងពីតូចមកថា កូនគួរគោរពឪពុកម្ដាយរបស់ខ្លួន។ គ្រូតែងតែបង្រៀនក្មេងតូចៗថា នៅពេលធំ ត្រូវសងគុណឪពុកម្ដាយ ហើយកុំឲ្យភ្លេចគុណរបស់លោកទាំងពីរជាពិសេសនៅពេលដែលគាត់ចាស់។

ដើម្បីខំសងគុណនោះ អ្នកកាន់សាសនាតែងតែធ្វើបុណ្យផ្សេងៗជូនដល់ឪពុកម្ដាយរបស់ខ្លួនមុន និងក្រោយពេលគាត់ស្លាប់។ ពួកគេធ្វើបុណ្យទាំងនេះ ដើម្បីសំដែងការគោរពប្រតិបត្តិចំពោះឪពុកម្ដាយរបស់គេ។ ម្យ៉ាងវិញទៀត អ្នកកាន់សាសនាទាំងនោះរំពឹងថា បុណ្យដែលពួកគេធ្វើនោះ នឹងជួយឪពុកម្ដាយបន្ទាប់ពីគាត់ស្លាប់ទៅ។ យោងតាមសាសនាបុណ្យដែលគេធ្វើនោះនឹងជួយឲ្យមានសេចក្ដីសុខ និងសេចក្ដីចម្រើន នៅក្នុងជីវិតនាពេលបច្ចុប្បន្ននេះ ទាំងជាតិក្រោយផង។

អ្នកជឿលើព្រះយេស៊ូវក៏យកចិត្តទុកដាក់យ៉ាងខ្លាំង ចំពោះការគោរពប្រតិបត្តិឪពុកម្ដាយរបស់ខ្លួនផងដែរ។ អ្នកជឿលើព្រះអង្គម្ចាស់យេស៊ូវ មានចិត្ត ឬឆន្ទៈយ៉ាងពិតប្រាកដក្នុងការគោរពឪពុកម្ដាយ ពីព្រោះព្រះបានមានបន្ទូលមកកាន់មនុស្សលោកយ៉ាងច្បាស់លាស់ថា ៖

**«ចូរឲ្យគោរពប្រតិបត្តិដល់ឪពុកម្ដាយ»**

«ក្មេងរាល់គ្នាអើយ ចូរស្ដាប់បង្គាប់ឪពុកម្ដាយក្នុងគ្រប់ការទាំងអស់ ដ្បិតព្រះអម្ចាស់ទ្រង់សព្វព្រះហឫទ័យយ៉ាងដូច្នោះឯង»[១]



ព្រះគម្ពីរចែងទុកថា នៅពេលដែលព្រះអង្គបានបង្កើតមនុស្សលោក កាលពីដើមដំបូងបង្អស់នោះ ព្រះបានដាក់ច្បាប់របស់ទ្រង់[២] ក្នុងចិត្តរបស់មនុស្សរួចទៅហើយ។ ម្ល៉េះហើយ ប្រសិនបើលោកអ្នកធ្វើដំណើរទៅប្រទេសផ្សេងណាមួយក៏ដោយ ហើយសួរគេថា តើកូនត្រូវគោរពឪពុកម្ដាយរបស់ខ្លួនដែរឬទេ? ស្ទើរតែ ១០០% ពិតជាឆ្លើយថា ពួកគេត្រូវតែគោរពប្រតិបត្តិដល់ឪពុកម្ដាយ។ ហេតុអ្វីបានជាមនុស្សលោកទាំងមូលដឹងថា ការគោរពប្រតិបត្តិឪពុកម្ដាយជាអំពើដែលល្អ? ពីព្រោះមនុស្សលោកមានព្រះពិតតែមួយ ជាព្រះដ៏ជាប្រភពនៃជីវិតទាំងអស់ ដែលបង្កើតយើងគ្រប់គ្នា។

ច្បាប់ ឬក្រឹត្យវិន័យអំពីការគោរពឪពុកម្ដាយសំខាន់ណាស់នៅចំពោះព្រះ។ ហេតុអ្វី? ពីព្រោះព្រះដែលបានបង្កើតយើងមកនោះ ទ្រង់បានតែងតាំងឪពុកម្ដាយឲ្យធ្វើជាអ្នកគ្រប់គ្រងលើកូនៗរបស់គាត់ដែរ។ ព្រះជាអ្នកដែលបានបង្កើតមនុស្សប្រុសស្រី អាពាហ៍ពិពាហ៍ គ្រួសារ និងសង្គម ដូច្នេះ កាលណាកូនមិនស្ដាប់បង្គាប់ ឬមិនគោរព

---

[១] ដកស្រង់ចេញពីព្រះគម្ពីរព្រះយេស៊ូវ និក្ខមនំ ២០:១២; កូល៉ុស ៣:២០។

[២] ច្បាប់របស់ព្រះ ឬព្រះធម៌របស់ព្រះយេស៊ូវនោះ អ្នកជឿលើព្រះយេស៊ូវហៅថា ក្រឹត្យវិន័យ ព្រះបន្ទូលរបស់ព្រះ បញ្ញត្ត ឬព្រះគម្ពីរព្រះអង្គ។

ឪពុកម្ដាយរបស់ខ្លួនទេនោះ មានន័យថា កូនក៏មិនស្ដាប់បង្គាប់ ហើយមិនគោរពដល់ព្រះជាម្ចាស់ដែរ។ ព្រះគម្ពីរព្រះចែងថា ៖

> **«ក្មេងរាល់គ្នាអើយ ចូរស្ដាប់បង្គាប់មាតាបិតាខ្លួនក្នុងព្រះអម្ចាស់ ដ្បិតធ្វើដូច្នោះទើបបានត្រូវ។ ចូរគោរពប្រតិបត្តិដល់មាតាបិតាខ្លួន»**[៣]

យើងទាំងអស់គ្នាដឹង ក៏យល់រួចទៅហើយថា ក្រឹត្យវិន័យនេះល្អ ប៉ុន្តែស្ទើរតែគ្រប់គ្នាមិនអាចធ្វើតាមបានទេ។ យើងទាំងអស់គ្នាតែងតែធ្លាក់មិនគោរពឪពុកម្ដាយ តមាត់



ជាមួយគាត់ លួចលាក់ពីឪពុកម្ដាយ ប្រមាថមើលងាយ លួចពីគាត់ និយាយមិនល្អ ជេរគាត់ក្នុងចិត្ត រមិលគុណ មិនស្ដាប់បង្គាប់ និងធ្វើឲ្យឪពុកម្ដាយខ្មាសគេ។ យើងទាំងអស់គ្នាមានទោសចំពោះព្រះ ពីព្រោះចិត្ត មាត់ និងការប្រព្រឹត្តផ្សេងៗទៀតរបស់យើងដែរ។

អ្នកខ្លះ គេស្មានថា គេអាចសងគុណឪពុកម្ដាយ និងគោរពគាត់បាន នៅពេលដែលគាត់ចូលមរណៈភាព ឬបន្ទាប់ពីលោកទាំងពីរស្លាប់ភ្លាម នោះដោយការសែន អុចធូប ឬធ្វើបុណ្យផ្សេងៗ។ ព្រះគម្ពីរព្រះយេស៊ូវពន្យល់ប្រាប់យ៉ាងច្បាស់ថា នៅពេលមនុស្សស្លាប់ ភ្លាមនោះមនុស្សគ្រប់រូបនឹងឡើងទៅស្ថានសួគ៌នៅជាមួយព្រះ ឬធ្លាក់ទៅស្ថាននរក ដើម្បីទទួលទោសរបស់ខ្លួន។ ដូច្នេះ អ្នកដែលនៅរស់មិនអាចជួយអ្នកស្លាប់ ឬទំនាក់ទំនងជាមួយគាត់ទៀតបានឡើយ គឺហួសពេលទៅហើយ។ ដ្បិតព្រះ

[៣] ដកស្រង់ចេញពីព្រះគម្ពីរព្រះយេស៊ូវ អេភេសូរ ៦:១-២។

**«បានតម្រូវឲ្យមនុស្សទាំងអស់ស្លាប់១ដង រួចសឹមជាប់សេចក្ដីជំនុំជំរះ»**[៤] *ដោយសារការសែនព្រេនដល់មនុស្សដែលបានស្លាប់ហើយនោះ ឥតប្រយោជន៍ដល់គាត់ទេ នោះបានជាអ្នកជឿលើព្រះយេស៊ូវឈប់សែនព្រេនដូច្នេះ។*

ចំពោះអ្នកជឿលើព្រះយេស៊ូវវិញ អ្វីដែលសំខាន់ជាងគេនោះ គឺការគោរពប្រតិបត្តិឪពុកម្ដាយរបស់ខ្លួន នៅពេលដែលគាត់នៅរស់។ អ្នកជឿលើព្រះយេស៊ូវ ទោះបីជាគាត់នៅជិត ឬឆ្ងាយក៏ដោយ ក៏គាត់នៅតែមានការយកចិត្តទុកដាក់ស្ដាប់បង្គាប់ឪពុកម្ដាយ គាត់



តែងតែមានសេចក្ដីស្រឡាញ់ មានចិត្តផ្គត់ផ្គង់ចំណីអាហារឲ្យ ទំនុកបម្រុង និងគោរពលោកទាំងពីរ។ ហើយនៅពេលដែលឪពុកម្ដាយស្លាប់ អ្នកជឿព្រះយេស៊ូវរៀបចំធ្វើបុណ្យយ៉ាងល្អ ដើម្បីរំលឹកគុណដល់ឪពុកម្ដាយ ហើយរួមគ្នាជួយសំរាលទុក្ខ។

របៀបមួយទៀត ដែលអ្នកជឿព្រះយេស៊ូវគោរពឪពុកម្ដាយ គឺដើរតាមផ្លូវសុចរិតរបស់ព្រះ។ នៅពេលកូនធំឡើង បើសិនជាកូនដើរក្នុងប្រាជ្ញារបស់ព្រះ ហើយបង្កើតគ្រួសារដែលដើរតាមសេចក្ដីសុចរិតរបស់ព្រះ ដូចជាសេចក្ដីស្រឡាញ់ ស្មោះត្រង់ស្លូតបូត មេត្រីភាព អត់ធ្មត់ សុភាព សប្បុរស លទ្ធផលគឺឪពុកម្ដាយនឹងមានចិត្តរីករាយ និងសេចក្ដីអំណរដោយសារកូននោះ។ បើលោកទាំងពីរខូចរួចហើយ បើកូន

[៤] ដកស្រង់ចេញពីព្រះគម្ពីរព្រះយេស៊ូវ ហេព្រើរ ៩:២៧។

ដើរក្នុងប្រាជ្ញានៃព្រះ ហើយនាំកូនខ្លួនឲ្យដើរតាមដែរ លទ្ធផល កូនលើកតំកើង ហើយផ្តល់កិត្តិយសដល់ឪពុកម្តាយ។ ព្រះគម្ពីរចែងថា ៖

«កូនចៅជាមកុដដល់មនុស្សចាស់ៗ ហើយឪពុកជាទីអំនួតរបស់ពួកកូន។»

«កូនល្ងីល្ងើជាហេតុឲ្យឪពុកកើតទុក្ខព្រួយ ហើយជាទីជូរល្វីងដល់ម្តាយដែលបង្កើតវាមក។»

«ឪពុកនៃមនុស្សសុចរិត នឹងមានចិត្តរីករាយយ៉ាងខ្លាំង ហើយអ្នកណាដែលបង្កើតកូនមានប្រាជ្ញា នោះនឹងមានសេចក្តីអំណរដោយសារកូននោះ។ ដូច្នេះ ចូរបើកឱកាសឲ្យឪពុកម្តាយឯងបានរីករាយចុះ ហើយឲ្យអ្នកដែលសំរាលឯងមកនោះមានចិត្តសប្បាយផង។»[៥]



[៥] ដកស្រង់ចេញពីព្រះគម្ពីរព្រះយេស៊ូវ សុភាសិត ១៧:៦, ២៥; ២៣:២៤-២៥។

គ្មាននរណាម្នាក់ដែលអានកូនសៀវភៅនេះ ដែលចង់មានឈ្មោះថា ជាអ្នករមិលគុណឪពុកម្ដាយខ្លួនទេ។ តើលោកអ្នកដឹងទេ? យើងទាំងអស់គ្នាជាអ្នករមិលគុណឪពុកម្ដាយរួចទៅហើយ ទោសរបស់យើងធ្ងន់ណាស់។ យើងដឹងហើយអំពីការដឹងគុណឪពុកម្ដាយ ប៉ុន្តែមិនសូវបានធ្វើទេ។

## តើអ្នកណាមានគុណធ្ងន់ជាងគេដល់យើង?

តាមពិត យើងទាំងអស់គ្នាមានការរមិលគុណមួយយ៉ាងធំ គឺជាការមិនដឹងគុណព្រះដែលបានបង្កើតព្រលឹងវិញ្ញាណរបស់យើងមក។ ព្រះជាឪពុកម្ដាយធំរបស់មនុស្សលោក ហើយយើងទាំងអស់គ្នាជាកូនរបស់ព្រះអង្គដែរ។ លោកអ្នកប្រើរបស់គ្រប់បែបយ៉ាង ដែលព្រះបានបង្កើត ហើយប្រទានមកឲ្យយើងរៀងរាល់ថ្ងៃ ដោយរមិលគុណដល់ទ្រង់ ដូចជាខ្យល់ដង្ហើម ទឹកភ្លៀង រាងកាយដ៏អស្ចារ្យរបស់មនុស្ស ទឹកដើម្បីដាំដំណាំ គ្រប់ទាំងសត្វ បន្លែ ផ្លែឈើ និងផ្កា។ ទោះបីជាថ្ងៃ លោកខែ និងផ្កាយរាប់មិនអស់នៅលើមេឃក៏ដោយ សុទ្ធតែជាស្នាព្រះហស្តរបស់ព្រះ។ ព្រះបានបង្កើតឪពុកម្ដាយ និងយាយតារបស់លោកអ្នកដែរ។ មិនតែប៉ុណ្ណោះនោះសោត របស់ទាំងអស់ដែលទ្រង់បានបង្កើតនោះ ស្ថិតស្ថេររាល់ថ្ងៃនេះដោយសារទ្រង់ដែរ។ ដូច្នេះហើយ ព្រះអង្គមានគុណធ្ងន់ណាស់! ប៉ុន្តែមនុស្សលោកមិនបានតំកើងទ្រង់ទេ ៖

> **«ព្រោះកាលគេបានស្គាល់ព្រះ នោះគេមិនបានតំកើងទ្រង់ ទុកជាព្រះទេ ក៏មិនដឹងគុណទ្រង់ដែរ»**[៦]

[៦] ដកស្រង់ចេញពីព្រះគម្ពីរព្រះយេស៊ូវ រ៉ូម ១:២១។

ព្រះអង្គបរិសុទ្ធ និងយុត្តិធម៌ ដូច្នេះ ព្រះអង្គមានសេចក្ដីក្រោធនូវចំពោះមនុស្សលោក ពីព្រោះអំពើបាប ការរមិលគុណរបស់គេ និងអស់ទាំងអំពើបាបឯទៀតៗដែលខ្លួនគេ បានប្រព្រឹត្ត។ ជាការពិតណាស់ កូនទាំងអស់ត្រូវតែគោរពប្រតិបត្តិដល់ឪពុកម្ដាយខ្លួន ពីព្រោះលោកទាំងពីរជាអ្នកមានគុណរបស់យើង។ ប៉ុន្តែមានម្នាក់ដែលមានគុណធ្ងន់ជាងគេ ច្រើនជាងឪពុកម្ដាយខាងសាច់ឈាមទៀត គឺជាព្រះដែលបានបង្កើតយើងមក[៧] ហេតុនេះហើយ យើងត្រូវគោរពប្រតិបត្តិដល់ព្រះអង្គទ្រង់។ ដោយសារមិនគោរពហើយរមិលគុណព្រះវិញនោះ មនុស្សយើងសមនឹងទទួលទោសដ៏ធ្ងន់ណាស់។

ប៉ុន្តែ អរព្រះគុណព្រះ ដែលទ្រង់បានរៀបចំផ្លូវជួយសង្គ្រោះមនុស្សលោក ដែលពោរពេញដោយអំពើបាបនោះឲ្យទទួលសេចក្ដីស្រឡាញ់ និងមេត្តាករុណារបស់ព្រះវិញ។ ព្រះអង្គជ្រាបថា មនុស្សសង្គ្រោះខ្លួនឯងដោយខំកាន់ធម៌សាសនាមិនបានទេ ដូច្នេះហើយព្រះអង្គបានបន្ទាបព្រះអង្គទ្រង់ យាងមកពីស្ថានសួគ៌ ចាប់កំណើតជាមនុស្ស ដើម្បីសង្គ្រោះមនុស្សវិញ។ នៅពេលដែលព្រះប្រសូតមក មាតាទ្រង់បានថ្វាយព្រះនាមតាមដែលទេវតាបានប្រាប់ថា «*យេស៊ូវ*» ដែលរាល់ថ្ងៃអ្នកជឿព្រះហៅថា ព្រះយេស៊ូវគ្រីស្ទ។ ក្នុងភាពជាមនុស្ស ព្រះអង្គកើតមកគ្មានបាប ហើយទ្រង់រស់នៅក្នុងភាពបរិសុទ្ធរហូតដល់សុគត។ ប្រហែល ៧៥០ ឆ្នាំមុនគ្រិស្តសករាជ ព្រះគម្ពីរបានថែងថា ព្រះអង្គសង្គ្រោះនឹងត្រូវឲ្យគេសម្លាប់ ហើយព្រះអង្គនឹងទទួលទោសរបស់មនុស្សនៅលើរូបកាយរបស់ទ្រង់ផ្ទាល់ ៖

[៧] ខ្លះហៅព្រះដែលបានបង្កើតអ្វីៗទាំងអស់នេះ គឺព្រះអាទិករ ឬព្រះអាទិទេព។

«តែទ្រង់ត្រូវរបួស ដោយព្រោះអំពើរំលងរបស់យើង ក៏ត្រូវវាយជាំ ដោយព្រោះអំពើទុច្ចរិតរបស់យើងទេ ឯការវាយផ្ចាលដែលនាំឲ្យយើងបានជាមេត្រី នោះបានធ្លាក់ទៅលើទ្រង់ ហើយយើងរាល់គ្នាបានប្រោសឲ្យជា ដោយសារស្នាមរំពាត់នៅអង្គទ្រង់។ យើងទាំងអស់គ្នាបានទាសចេញដូចជាចៀម គឺយើងបានបែរចេញទៅតាមផ្លូវយើងរៀងខ្លួន ហើយព្រះអម្ចាស់បានទំលាក់អំពើទុច្ចរិតរបស់យើងទាំងអស់គ្នាទៅលើទ្រង់»[៨]

ព្រះអង្គសង្គ្រោះត្រូវទទួល «**អំពើទុច្ចរិតរបស់យើងទាំងអស់គ្នាទៅលើទ្រង់**» មានន័យថា ទ្រង់ត្រូវសងថ្លៃលោះបាបរបស់យើង ដើម្បីឲ្យយើងបានរួច។ កិច្ចការទាំងអស់នេះបានសម្រេចហើយនៅពេលដែលព្រះយេស៊ូវសុគតនៅលើឈើឆ្កាងជាង ២.០០០ ឆ្នាំ មុន។ បន្ទាប់ពីទ្រង់សុគត ទ្រង់រស់ពីស្លាប់ឡើងវិញដែរ ពីព្រោះទ្រង់បានឈ្នះអំពើបាប និងសេចក្ដីស្លាប់ ហើយព្រះអង្គបានឡើងទៅស្ថានសួគ៌វិញ។

អស់អ្នកណាដែលបន្ទាបខ្លួន កែប្រែចិត្តទទួលព្រះអង្គ ជាព្រះអង្គសង្គ្រោះ និងជាម្ចាស់ជីវិតរបស់ខ្លួនដោយជំនឿ អ្នកនោះនឹងស្គាល់សេចក្ដីស្រឡាញ់របស់ទ្រង់ មិនឃើញសេចក្ដីក្រោធរបស់ទ្រង់ទៀតទេ។ អ្នកជឿព្រះផ្លាស់ប្រែពីលក្ខណៈជាអ្នករមិលគុណដល់ព្រះ ទៅជាអ្នកដឹងគុណព្រះទៅវិញ ហើយមានចិត្តដើរតាមព្រះអង្គរហូតដល់ឃើញព្រះអង្គទល់មុខនិងមុខនៅស្ថានសួគ៌។ ព្រះមានបន្ទូលទៅកាន់មនុស្សលោកថា ៖

[៨] ដកស្រង់ចេញពីព្រះគម្ពីរព្រះយេស៊ូវ អេសាយ ៥៣:៥-៦។

**«អស់ទាំងមនុស្សនៅចុងផែនដីអើយ ចូរមើលមកអញ ហើយទទួលសេចក្ដីសង្គ្រោះចុះ ដ្បិតអញនេះជាព្រះ ឥតមានព្រះឯណាទៀតឡើយ»**[៩]

ដូច្នេះ នៅពេលដែលយើងគោរពឪពុកម្ដាយ យើងកំពុងតែគោរពព្រះយេស៊ូវដែរ ហើយនៅពេលដែលយើងមិនគោរពឪពុកម្ដាយ យើងកំពុងតែមិនគោរពព្រះយេស៊ូវដូចគ្នា។ ហេតុនោះហើយបានជាអ្នកជឿលើព្រះយេស៊ូវទាំងអស់គ្នាត្រូវតែគោរពឪពុកម្ដាយរបស់ខ្លួន តាមដែលព្រះគម្ពីរបានចែងទុកមក។

*សូមឲ្យព្រះយេស៊ូវប្រទានពរឲ្យលោកអ្នក ដែលបានឆ្លៀតពេលអាន ហើយគិតពិចារណាតាមព្រះគម្ពីររបស់ព្រះអង្គទាំងអស់នេះ។ សូមព្រះអង្គនាំឲ្យលោកអ្នកបានស្គាល់ទ្រង់ជាម្ចាស់ ជាព្រះអង្គសង្គ្រោះរបស់ខ្លួនផងដែរ។*

[៩] ដកស្រង់ចេញពីព្រះគម្ពីរព្រះយេស៊ូវ អេសាយ ៤៥:៥, ៦, ២២។